# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥*

**អនុក្រឹត្យលេខ ៤៤ អនក្រ/បក**

**ស្តីពីការបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ .

**សំរេច**

**មាត្រា ១ :** ត្រូវបានបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្ត **មណ្ឌលគិរី រតនៈគិរី ព្រះវិហារ** និង **ឧត្តរមានជ័យ** ស្ថិតនៅក្រោមការគ្រប់គ្រង និងបញ្ជាដឹកនាំផ្ទាល់របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះ ហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤៥ អនក្រ.បក**

**ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ច**

**របស់រាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ភារកិច្ច និង សមត្ថកិច្ចរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុក អធិការកិច្ច
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែល រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តកាលពីថ្ងៃទី ១៩ ខែកក្កដា